ស្ថានទូតជប៉ុន
ប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

លេខ. 30 PR-17/EoJ ថ្ងៃទី៣ ខែតុលា ឆ្នាំ២០១៧

# ពិធីចុះហត្ថលេខាលើលិខិតប្តូរសារស្តីពីការផ្តល់ជំនួយឥតសំណងរបស់ជប៉ុន

*ថ្ងៃអង្គារ ទី៣ ខែតុលា ឆ្នាំ២០១៧ ម៉ោង១០:០០ព្រឹក*

*នៅទីស្តីការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ*

ឆ្លើយតបទៅនឹងសំណើរសុំរបស់រាជរដ្ឋាភិបាលកម្ពុជា និងដោយឈរលើទស្សនៈដើម្បីជួយជំរុញការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចរបស់ព្រះរាជាណាចក្រកម្ពុជា រដ្ឋាភិបាលជប៉ុនបានសម្រេចផ្តល់ជំនួយឥតសំណងដែលមានទឹកប្រាក់សរុបបីពាន់ប្រាំបួនរយសែសិបពីរលានយ៉េន **(¥3,942,000,000)** ឬប្រមាណជាសាមសិបប្រាំលានដុល្លាអាមេរិក **(USD35,000,000)** ដើម្បីអនុវត្តគម្រោង"សាងសង់ស្ពានបន្ទាន់នៅតំបន់រងគ្រោះដោយសារទឹកជំនន់"។ គម្រោងនេះនឹងសាងសង់ស្ពានចំនួនប្រាំពីរ និងផ្លូវភ្ជាប់ស្ពាន ដោយស្ពានចំនួនពីរស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ១១ក្នុងខេត្តព្រៃវែង និងស្ពានចំនួនប្រាំទៀតស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ៧៣ក្នុងខេត្តក្រចេះ។

លិខិតប្តូរសារនៃគម្រោងជំនួយឥតសំណងនេះត្រូវបានចុះហត្ថលេខារវាង **ឯកឧត្តម ប្រាក់ សុខុន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និង**ឯកឧត្តម ហូរីណូអ៊ុជិ ហ៊ីដេហ៊ីសា** ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជានៅម៉ោង១០:00 ព្រឹក ថ្ងៃទី៣ ខែតុលា ឆ្នាំ២០១៧ នៅទីស្តីការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

គម្រោងនេះមានបំណងធានានូវការដឹកជញ្ជូន និងឡជីស្ទីកប្រកបដោយសុវត្ថិភាព រលូន និងស្ថិរភាពក្នុងតំបន់រងគ្រោះដោយសារទឹកជំនន់តាមរយៈការសាងសង់ស្ពានថ្មីជំនួសឲ្យស្ពានបណ្តោះអាសន្នដែលអាចរួមចំណែកលុបបំបាត់ភាពងាយរងគ្រោះដោយសារគ្រោះធម្មជាតិក្នុងតំបន់គោលដៅ។ មិនត្រឹមតែប្រជាជនកម្ពុជាប៉ុណ្ណោះទេ អ្នកដំណើរអន្តរជាតិក៏នឹងប្រើប្រាស់ស្ពានទាំងនេះផងដែរ។ យើងរំពឹងថា គម្រោងនេះនឹងលើកស្ទួយសេដ្ឋកិច្ច និងជីវភាពប្រជាជនក្នុងព្រះរាជាណាចក្រកម្ពុជា និងជួយពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាងរដ្ឋាភិបាលជប៉ុន និងរាជរដ្ឋាភិបាលកម្ពុជា។

ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
លេខ 194 មហាវិថីព្រះនរោត្តម ☎ (023) 217.161-4 ទូរសារ: (023) 214.330
អ៊ីម៉ែល: eco.jpn@pp.mofa.go.jp
គេហទំព័រ: www.kh.emb-japan.go.jp